គណៈកម្មាធិការដើម្បីការបោះឆ្នោតដោយសេរី និងយុត្តិធម៌ នៅកម្ពុជា
Committee for Free and Fair Elections in Cambodia
ខុមហ្វ្រែល COMFREL

ថ្ងៃទី១៩ ខែមីនា ឆ្នាំ២០១២

# សេចក្តីប្រកាសព័ត៌មាន

# ស្តីពី

## លទ្ធផលសិក្ខាសាលាសម្លេងម្ចាស់ឆ្នោតឃុំរមណីយ ស្រុករវៀង ខេត្តព្រះវិហារ

ដោយមានការគាំទ្រពីគណៈកម្មាធិការខុមហ្វ្រែល សហការជាមួយនឹង **សមាគមជនជាតិដើមភាគតិចកួយ** បានរៀបចំសិក្ខាសាលាសម្លេងម្ចាស់ឆ្នោតមួយ ស្តីពី **ការកំណត់តម្រូវការជាអាទិភាពក្នុងឃុំ-សង្កាត់ដាច់ស្រយាល** ដែលធ្វើឡើងនៅ**ឃុំរមណីយ ស្រុករវៀង ខេត្តព្រះវិហារ** កាលពីថ្ងៃទី១២ មីនា ឆ្នាំ២០១២។ មានអ្នកមានសិទ្ធិបោះឆ្នោតប្រមាណ **៦០ នាក់ (៣១%ជាស្ត្រី និង៦៣%ជាជនជាតិដើមភាគតិចកួយ)** ពីគ្រប់ភូមិក្នុងឃុំ ដែលរួមមាន តំណាងសហគមន៍ តំណាងគណបក្សនយោបាយប្រចាំឃុំ សមាជិកក្រុមប្រឹក្សាឃុំ អាជ្ញាធរភូមិ អង្គការមូលដ្ឋាន និងប្រជាពលរដ្ឋនៅក្នុងឃុំបានចូលរួមពិភាក្សានៅក្នុងសិក្ខាសាលានេះ។

ប្រជាពលរដ្ឋដែលចូលរួមសិក្ខាសាលាស្ទើរតែ ១០០% បានបោះឆ្នោតគាំទ្រតម្រូវការជាអាទិភាពទាំង៥ នៅក្នុងឃុំ ដែលស្នើឱ្យក្រុមប្រឹក្សាឃុំបច្ចុប្បន្នយកចិត្តទុកដាក់ដោះស្រាយ និង/ឬ គណបក្សនយោបាយ ទទួលយកដើម្បីដាក់បញ្ចូលទៅក្នុង កម្មវិធីនយោបាយរបស់ខ្លួនក្នុងការបោះឆ្នោតឃុំ-សង្កាត់ខាងមុខ។

| តម្រូវការជាអាទិភាព ទាំង ៥ ក្នុង ឃុំរមណីយ ស្រុករវៀង ខេត្តព្រះវិហារ |
|---|
| **១. ការសាងសង់ផ្លូវថ្មី លូ និងស្ពានចំនួន៥ខ្សែ**<br>▪ ស្នើសុំសាងសង់ផ្លូវលំ**ចំនួន៥ខ្សែ** ដែលផ្លូវនីមួយៗមានទទឹង១៥ម៉ែត្រដូចគ្នា និងបណ្តោយខុសគ្នាគឺ៖<br>○ **ខ្សែទី១** មានប្រវែង៣០០០ម៉ែត្រ ទទឹង១៥ម៉ែត្រ ចាប់ពីសាលារៀនអនុវិទ្យាល័យភ្នំដែក ទៅដល់ភូមិរំចេកថ្មី ក្នុងនោះមានប្រើលូចំនួន៦កន្លែង ដោយក្នុង១កន្លែងៗប្រើលូចំនួន៨កង់។ សូមចាប់ផ្តើមសាងសង់នៅឆ្នាំ២០១២ និងបញ្ចប់នៅឆ្នាំ២០១៣។<br>○ **ខ្សែទី២** មានប្រវែង២០០០ម៉ែត្រ ទទឹង១៥ម៉ែត្រ ចាប់ពីភូមិរំចេកថ្មី ទៅដល់ភូមិរំចេកចាស់ ក្នុងនោះមានប្រើលូចំនួន៣កន្លែង ដោយក្នុង១កន្លែងៗប្រើ**លូ**ចំនួន៨កង់ និង**ស្ពាន**ចំនួន១កន្លែង មានប្រវែង២០ម៉ែត្រ ទទឹង១៥ម៉ែត្រ ។ សូមចាប់ផ្តើមសាងសង់នៅឆ្នាំ២០១២ និងបញ្ចប់នៅឆ្នាំ២០១៣។<br>○ **ខ្សែទី៣** មានប្រវែង២០០០ម៉ែត្រ ទទឹង១៥ម៉ែត្រ ក្នុងនោះមានប្រើលូចំនួន៣កន្លែង ដោយក្នុង១កន្លែងៗប្រើ**លូ**ចំនួន៨កង់ និង**ស្ពាន**ចំនួន១កន្លែង មានប្រវែង២០ម៉ែត្រ ទទឹង១៥ម៉ែត្រ ចាប់ពីសាលារៀនអនុវិទ្យាល័យភ្នំដែក ទៅដល់ភូមិរំចេកចាស់។ សូមចាប់ផ្តើមសាងសង់នៅឆ្នាំ២០១២ និងបញ្ចប់នៅឆ្នាំ២០១៣។<br>○ **ខ្សែទី៤** មានប្រវែង២០០០ម៉ែត្រ ទទឹង១៥ម៉ែត្រ ចាប់ពីភូមិរំចេកចាស់ ទៅដល់សាលាបឋមសិក្សាភ្នំដែក ស្ថិតនៅក្នុងភូមិភ្នំដែក មានប្រើ**លូ**ចំនួន៣កន្លែង ដោយក្នុង១កន្លែងៗប្រើ**លូ**ចំនួន៨កង់ ។ សូមចាប់ផ្តើមសាងសង់នៅឆ្នាំ២០១២ និងបញ្ចប់នៅឆ្នាំ២០១៣។ |

**Vision** : A democratic society that democratization in particular democratic elections are promoted and qualified to bring benefits to people.

ទីស្នាក់ការកណ្តាល ៖ ផ្ទះលេខ ១៣៨ ផ្លូវ ១២២ សង្កាត់ ទឹកល្អក់ ១ ខណ្ឌ ទួលគោក រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
Central Office : #138, Street. 122, TeukLaak I, TuolKork, Phnom Penh, CAMBODIA.
P.O. Box1145, Phone : (855) 23 884 150 Fax: (855) 23 885 745 E-mail : comfrel@online.com.kh Website: www.comfrel.org

- **ខ្សែទី៥** មានប្រវែង១៥០០ម៉ែត្រ ទទឹង១៥ម៉ែត្រ ចាប់ពីភូមិអូរពោធិ៍ ទៅដល់ភូមិជីអោត ក្នុងនោះមានប្រើ**លូ**ចំនួន២កន្លែង ដោយក្នុង១កន្លែងៗប្រើលូចំនួន៨កង់។ សូមចាប់ផ្តើមសាងសង់នៅឆ្នាំ២០១២ និងបញ្ចប់នៅឆ្នាំ២០១៣។

**២. ការស្នើសុំអណ្តូងទឹក បង្គន់អនាម័យ និងជីកស្រះ**

- សុំអណ្តូងស្នប់**ចំនួន៦០**អណ្តូង ក្នុងនោះសម្រាប់ភូមិភ្នំដែក១៥អណ្តូង ភូមិរំចេក១៥អណ្តូង ភូមិអូរពោធិ៍ ១០អណ្តូង ភូមិជីអោត១០អណ្តូង និងភូមិស្រែធ្នង់១០អណ្តូង។ សូមចាប់ផ្តើមសាងសង់នៅឆ្នាំ២០១២ និងបញ្ចប់នៅឆ្នាំ២០១៣។
- សុំបង្គន់អនាម័យ**ចំនួន២៥០**បង្គន់ ក្នុងនោះសម្រាប់ភូមិភ្នំដែក៥០បង្គន់ ភូមិរំចេក៥០បង្គន់ ភូមិអូរពោធិ៍ ៥០បង្គន់ ភូមិជីអោត៥០បង្គន់ និងភូមិស្រែធ្នង់៥០បង្គន់។ សូមចាប់ផ្តើមសាងសង់នៅឆ្នាំ២០១២ និងបញ្ចប់នៅឆ្នាំ២០១៤។
- សុំជីកស្រះថ្មីចំនួន**៥ស្រះ** ដែលស្រះនីមួយៗមានប្រវែង៤០ម៉ែត្រ ទទឹង៣ម៉ែត្រ និងជម្រៅ៥ម៉ែត្រ សម្រាប់ភូមិទាំង៥គឺៈ ភូមិភ្នំដែកចំនួនស្រះ១ ភូមិរំចេកចំនួនស្រះ១ ភូមិជំអោតចំនួនស្រះ១ ភូមិអូរពោធិ៍ ចំនួនស្រះ១ និងភូមិស្រែធ្នង់ចំនួនស្រះ១។ សូមចាប់ផ្តើមនៅឆ្នាំ២០១៣ និងបញ្ចប់នៅឆ្នាំ២០១៤។

**៣. ការស្នើសុំសាងសង់ប៉ុស្តិ៍សុខភាព និងគ្រូពេទ្យ**

- សុំសាងសង់**ប៉ុស្តិ៍សុខភាព**ចំនួន១កន្លែងធ្វើអំពីថ្ម ប្រក់ក្បឿង មាន៥បន្ទប់ បណ្តោយ២៥ម៉ែត្រ ទទឹង៥ ម៉ែត្រ ស្ថិតនៅចំណុចកណ្តាលភូមិអូរពោធិ៍។ សូមចាប់ផ្តើមសាងសង់នៅឆ្នាំ២០១៣ និងបញ្ចប់នៅឆ្នាំ ២០១៤។
- សុំ**គ្រូពេទ្យ**ចំនួន៦នាក់ មានជំនាញផ្នែកភ្នែក១នាក់ ធ្មប២នាក់ ពេទ្យជម្ងឺទូទៅ២នាក់ និងពេទ្យរបេង១ នាក់។ សូមចាប់ផ្តើមនៅឆ្នាំ២០១៤។

**៤. ការស្នើសុំសាងសង់សាលារៀន និងគ្រូបង្រៀន**

- សុំសាងសង់សាលាបឋមសិក្សាថ្មីចំនួន១កន្លែង នៅចំណុចកណ្តាលភូមិរំចេក ធ្វើអំពីថ្ម ប្រក់ក្បឿង មាន ៥បន្ទប់។ សូមចាប់ផ្តើមសាងសង់នៅឆ្នាំ២០១៣ និងបញ្ចប់នៅឆ្នាំ២០១៤។
- សុំគ្រូបង្រៀនបឋមសិក្សាចំនួន៥នាក់ សម្រាប់សាលាបឋមសិក្សាថ្មីនៅក្នុងភូមិរំចេក មានជំនាញកម្រិត បឋមសិក្សាចាប់ពីថ្នាក់ទី១ដល់ ថ្នាក់ទី៥។ សូមចាប់ផ្តើមនៅឆ្នាំ២០១៤។

**៥. ការស្នើសុំបើកវគ្គបណ្តុះបណ្តាលកសិកម្ម បង្កើតសហគមន៍ព្រៃឈើ និងពង្រីកដីលំនៅដ្ឋាន**

- សុំឲ្យមានការបើកវគ្គបណ្តុះបណ្តាលស្តីពីផ្នែកកសិកម្មចំនួន**៥វគ្គ** ពីការចិញ្ចឹមមាន់ ទា ជ្រូក ត្រី គោក្របី បណ្តុះផ្សិត និងជីកំប៉ុស សម្រាប់ភូមិភ្នំដែក១វគ្គ ភូមិរំចេក១វគ្គ ភូមិអូរពោធិ៍១វគ្គ ភូមិជំអោត១វគ្គ និងភូមិស្រែធ្នង់១វគ្គ។ សូមចាប់ផ្តើមនៅឆ្នាំ២០១២ និងបញ្ចប់នៅឆ្នាំ២០១៣។
- សុំឲ្យមានការផ្សព្វផ្សាយច្បាប់អំពើហិង្សាក្នុងគ្រួសារ ការជួញដូរស្ត្រីកុមារ ច្បាប់ភូមិបាល ច្បាប់ព្រៃឈើ និងបរិស្ថានចំនួន**៥វគ្គ** សម្រាប់ភូមិភ្នំដែក១វគ្គ ភូមិរំចេក១វគ្គ ភូមិអូរពោធិ៍១វគ្គ ភូមិជំអោត១វគ្គ និងភូមិស្រែធ្នង់១វគ្គ។ សូមចាប់ផ្តើមនៅឆ្នាំ២០១២ និងបញ្ចប់នៅឆ្នាំ២០១៣។
- ប្រជាពលរដ្ឋរស់នៅភ្នំដែក បានស្នើសុំទៅមន្ទីរដែលពាក់ព័ន្ធនានានៅខេត្ត ដើម្បីសុំបង្កើតសហគមន៍

ការពារព្រៃឈើនៅក្នុងភូមិភ្នំដែក។ សូមចាប់ផ្តើមនៅ២០១២ និងឲ្យបាននៅឆ្នាំ២០១៣។

- ស្នើសុំពង្រីកដីលំនៅដ្ឋានសម្រាប់៩០គ្រួសារ សម្រាប់ភូមិភ្នំដែក៣០គ្រួសារ ភូមិស្រែធ្នង់១៥គ្រួសារ ភូមិរំចេក៣០គ្រួសារ និងភូមិអូរពោធិ៍១៥គ្រួសារ។ សូមចាប់ផ្តើមនៅឆ្នាំ២០១២ និងឲ្យបាននៅឆ្នាំ២០១៣។

មុនពេលបញ្ចប់សិក្ខាសាលាមានកម្មវិធីប្រគល់របាយការណ៍ពីតម្រូវការជាអាទិភាពដល់អ្នកដឹកនាំគណបក្សនយោបាយប្រចាំឃុំ និងក្រុមប្រឹក្សាឃុំ។

លោក **សេង ឈៀង** តំណាងគណបក្សប្រជាជនកម្ពុជា និងជាប្រធានក្រុមប្រឹក្សាឃុំ បានមានប្រសាសន៍ថា «ខ្ញុំមានសេចក្តីរីករាយយ៉ាងខ្លាំង ហើយគាំទ្រទៅលើតម្រូវការអាទិភាពទាំង៥នេះ ឃុំក៏មានផែនការអភិវឌ្ឍន៍បន្តទៅមុខទៀតដែរ គឺគម្រោងអភិវឌ្ឍន៍ផ្លូវលំមានដល់ទៅ១៧គីឡូម៉ែត្រ តែឃុំទើបតែធ្វើបាន៥គីឡូម៉ែត្រប៉ុណ្ណោះ ហើយឃុំនឹងព្យាយាមធ្វើបន្តទៀត»។

លោក **សេក សុធា** តំណាងគណបក្សសមរង្ស៊ី និងជាជំទប់ទី១ បានមានប្រសាសន៍ថា «តម្រូវការអាទិភាពទាំង៥នេះ ខ្ញុំសូមគាំទ្រ និងឯកភាពទាំងស្រុង ហើយនឹងដាក់បញ្ចូលទៅក្នុងគោលនយោបាយរបស់គណបក្សរបស់លោក»។

លោក **ព្រំ ព្រិន** ជាតំណាងគណបក្សហ៊្វុនស៊ិនប៉ិច និងជាជំទប់ទី២ បានមានប្រសាសន៍ថា«ខ្ញុំសូមគាំទ្រទៅលើតម្រូវការទាំង៥ចំណុចនេះយ៉ាងខ្លាំង ខ្ញុំនឹងបញ្ចូលទៅក្នុងផែនការអភិវឌ្ឍឃុំ-សង្កាត់នាពេលខាងមុខនេះ ហើយលោកនឹងដាក់បញ្ចូលទៅក្នុងគោលនយោបាយគណបក្សរបស់លោកផងដែរ»។

**សិក្ខាសាលានេះមានគោលបំណងឲ្យម្ចាស់ឆ្នោតនៅតំបន់ដាច់ស្រយាលទទួលបាន៖**

១. ការយល់ដឹងអំពីសិទ្ធិតួនាទី និងកាតព្វកិច្ចរបស់ម្ចាស់ឆ្នោតក្នុងការស្វែងយល់ពីតម្រូវការជាអាទិភាពក្នុងការអភិវឌ្ឍន៍នូវមូលដ្ឋាន។

២. ផ្តល់ឱកាសឱ្យម្ចាស់ឆ្នោតចូលរួម ជជែកពិភាក្សា ដើម្បីកំណត់តម្រូវការអាទិភាពក្នុងឃុំ-សង្កាត់របស់ខ្លួន។

៣. តម្រូវការជាអាទិភាពក្នុងឃុំ-សង្កាត់ ដាច់ស្រយាលនឹងត្រូវបានចងក្រងជារបាយការណ៍ដែលអាចឱ្យសិក្ខាកាមងាយចងចាំដើម្បីចូលរួមតាមដានជម្រុញការអនុវត្តន៍របស់ក្រុមប្រឹក្សាឃុំ-សង្កាត់ និងការដាក់បញ្ចូលតម្រូវការក្នុងកម្មវិធីនយោបាយរបស់គណបក្សសម្រាប់ការបោះឆ្នោតឃុំ-សង្កាត់ឆ្នាំ២០១២។

សិក្ខាសាលានេះក៏បានទទួលការឧបត្ថម្ភមូលនិធិពីសហភាពអឺរុប (EU), OXFAM NOVIB, NPA និង Forum Syd

[1]សម្រាប់ព័ត៌មានបន្ថែមសូមទំនាក់ទំនង៖

១-លោក **ម្លូច មឿត** (មន្ត្រីផ្នែកបណ្តាញ និងវេទិកា)

ទូរស័ព្ទលេខ ៖ **០១២ ៤៧១ ៣២៦**

២-អ្នកស្រី **ហោច សុគន្ធា** (ជំនួយការផ្នែកបណ្តាញ និងវេទិកា)

ទូរស័ព្ទលេខ ៖ **០១៧ ៥៨៣ ៨៦៩**

<u>បេសកម្ម</u> ៖ បេសកកម្មរបស់ខុមហ្រ្វែល គឺជួយបង្កើតបរិយាកាសគួរជាទីពេញចិត្ត និងមានពត៌មានគ្រប់គ្រាន់ ទី១/**ដើម្បីឱ្យមានដំណើរការបោះឆ្នោតដោយសេរី និងយុត្តិធម៌**តាមរយៈការបញ្ចុះបញ្ចូល តស៊ូមតិ ដើម្បីទទួលបាននូវក្របខ័ណច្បាប់សមរម្យ, ការអប់រំដើម្បីផ្តល់ពត៌មានដល់អ្នកបោះឆ្នោត អំពីសិទ្ធិ និងសកម្មភាពចូលរួមសង្កេតការណ៍របស់ពួកគេ ដែលអាចរារាំងនូវភាពមិនប្រក្រតី ព្រមទាំងផ្តល់នូវរបាយការណ៍អង្កេតយ៉ាងទូលំទូលាយ និងឆាប់រហ័ស ដើម្បីអាចឲ្យមានការវាយតម្លៃលើដំណើរការ បោះឆ្នោតមួយដែលមិនលំអៀង និងមិនប្រកាន់បក្សពួក ទី២/ **ដើម្បីឱ្យមានអត្ថន័យនៃដំណាក់កាលក្រោយពេលបោះឆ្នោត** តាមរយៈការអប់រំ និងវេទិកាសាធារណៈក្នុងគោលបំណងជំរុញលើកទឹកចិត្តប្រជាពលរដ្ឋឱ្យចូលរួមក្នុងកិច្ចការនយោបាយ និងការធ្វើសេចក្តីសំរេចនានា ការតស៊ូមតិ/បញ្ចុះបញ្ចូលដើម្បីឱ្យមានការកែទម្រង់ ដំណើរការបោះឆ្នោតដែលបង្កើននូវគណនេយ្យភាព (ការទទួលខុសត្រូវ) របស់មន្ត្រីជាប់ឆ្នោត ព្រមទាំងផ្តល់នូវរបាយការណ៍អង្កេតយ៉ាងទូលំទូលាយ និងឆាប់រហ័ស ដើម្បីអាចឱ្យមានការវាយតម្លៃមួយដែលមិនលំអៀង និងប្រកាន់បក្សពួកទៅលើការបំពេញកម្មវិធីនយោបាយ និងដំណើរការអនុវត្តន៍ការងាររបស់មន្ត្រីជាប់ឆ្នោត។

---

[1] No 093